# សន្លឹកពត៌មានសាធារណៈ

Ottawa County Health Department

## ជំងឺបូទុយលីស្ទ

**តើជំងឺបូទុយលីស្ទជាអ្វី ?**

ជំងឺបូទុយលីស្ទ ជាជំងឺកំរមាន វាធ្វើអោយពិការសាច់ដុំដោយបណ្តាលមកពីជាតិពុលរបស់បាក់តេរីទៅលើសរសៃប្រសាទ ។ ជំងឺបូទុយលីស្ទ មានបីទំរង់ : ឆ្លងតាមចំណីអាហារ ដំបៅ និង ពោះវៀន ( កូនក្មេង) ។

ទំរង់ទាំងអស់នៃជំងឺនេះ អាចបណ្តាលអោយស្លាប់បាន ហើយវាទាមទារនូវការសង្គ្រោះបន្ទាន់ទាំងអស់ ។

**តើជំងឺបូទុយលីស្ទមានញឹកញាប់ឬទេ ?**

សហរដ្ឋអាមេរិក រាយការណ៏ថា ជាមធ្យម មានករណីជំងឺបូទុយលីស្ទចំនួន ១១០ករណី ក្នុងមួយឆ្នាំៗ ។ ក្នុងនោះមាន ប្រហែល ២៥% ឆ្លងតាមចំណីអាហារ ៧២% ឆ្លងតាមពោះវៀន និង ៣% ទៀតឆ្លងតាមដំបៅ ។

**តើជំងឺបូទុយលីស្ទឆ្លងតាមរបៀបណា ?**

ជំងឺបូទុយលីស្ទអាចឆ្លងតាមរយៈវិធីខាងក្រោមនេះ :

- ចំណីអាហារ
    - o អាហារដែលមានមេរោគ
    - o អាហារដែលមិនបានចំអិនត្រឹមត្រូវ រួមទាំងអាហារកំប៉ុងផង
- ដំបៅ
    - o មានការលូតលាស់នៃបាក់តេរីបូទុយលីស្ទ នៅក្នុងដំបៅ
    - o អ្នកប្រើថ្នាំញៀនតាមរយៈការចាក់
- ពោះវៀន ( កូនក្មេង)
    - o ហូបអាហារដែលមានស្ព័រលូតលាស់នៅក្នុងពោះវៀន រួចវាបញ្ចេញជាតិពុលបូទុយលីស្ទ

គេក៏អាចប្រើមេរោគបូទុយលីស្ទ ជាអាវុធជីវភេរវកម្ម ដោយធ្វើអោយមាន ការចំលងបាក់តេរីនេះតាមខ្យល់ ។

មិនមានការឆ្លងនៃបូទុយលីស្ទ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតទេ ។

**តើជំងឺបូទុយលីស្ទអាចមានរោគសញ្ញាអ្វីខ្លះ ?**

រោគសញ្ញាទូទៅនៃជំងឺនេះមាន :

- មើលឃើញរូបមួយចេញជាពីរ
- មើលឃើញស្រវាំង
- និយាយឡូលៗជាប់គ្នារដឹក
- ពិបាកលេប
- ស្ងួតមាត់
- ខ្សោយ ឬពិការសាច់ដុំ

*ជំងឺបូទុយលីស្ទឆ្លងតាមចំណីអាហារ :* តាមធម្មតា រោគសញ្ញាដំបូងច្រើនស្តែងឡើងក្នុងរយៈពី ១៨ ទៅ ៣៦ ម៉ោង ប៉ុន្តែវាអាចមានយ៉ាងឆាប់ក្នុងរយៈ ៦ ម៉ោង ឬ យ៉ាងយូរ ១៤ ថ្ងៃ ។

*ជំងឺបូទុយលីស្ទឆ្លងតាមពោះវៀន ( កូនក្មេង):* កុមារអាចហាក់ដូចជាអស់កំលាំង ហូបមិនសូវបាន ទល់លាមក យំខ្សោយ និងខ្សោយសាច់ដុំអវយវៈ ។

**តើគេធ្វើរោគវិនិច្ឆ័យជំងឺបូទុយលីស្ទតាមរបៀបណា ?**

គេស្រាវជ្រាវរកជំងឺបូទុយលីស្ទ តាមរយៈការពិនិត្យឈាម ឬលាមករបស់អ្នកជំងឺ និងតាមរយៈការធ្វើអត្តសញ្ញាណកម្មមន្ទីរពិសោធន៏ ទៅលើចំណីអាហារដែលមានមេរោគ ។

**តើគេព្យាបាលជំងឺបូទុយលីស្ទដូចម្តេច ?**

នៅដំណាក់កាលដំបូងនៃជំងឺ វេជ្ជបណ្ឌិតអាចព្យាបាលជំងឺនេះដោយប្រើថ្នាំប្រឆាំងនឹងជាតិពុល ដោយរារាំងសកម្មភាពរបស់ជាតិពុលនៅក្នុងឈាម ។

ប៉ុន្តែអ្នកជំងឺខ្លះ អាចត្រូវការដាក់អោយដកដង្ហើមតាមម៉ាស៊ីនជា ច្រើនសប្តាហ៏ ព្រមទាំងមានការថែទាំ និងព្យាបាលយ៉ាងដិតដល់ ។

**សំរាប់ពតិមានបន្ថែមស្តីអំពីជំងឺបូទុយលីស្ទ សូមទាក់ទង :**

Ottawa County Health Department
www.miOttawa.org

Centers for Disease Control and Prevention
www.bt.cdc.gov/agent/botulism/
ទូរស័ព្ទ : (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ : (616) 396-5266
ទូរសារ : (616) 393-5643
វ៉ិបសាយ : www.miOttawa.org